# **សង្ខេបសាលដីកាតុលាការកំពូល**

## **សំណុំរឿងព្រហ្មទណ្ឌ សាលដីកាលេខ ២០ ចុះថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០០៥ (ភាគ ៤១-៤៤)**

**១.ពាក្យគន្លឹះ៖** បទបន្លំលិខិតស្នាមឯកជន-ដីកាលើកលែងការចោទប្រកាន់-សក្ខីកម្មក្លែងក្លាយ-រដ្ឋប្បវេណីទាមទារដីនេះសម្រេចដោយតុលាការកំពូល-សាទុក្ខលើកទី១។

**២. អង្គហេតុ និង ដំណើរការនីតិវិធី៖** ជនជាប់ចោទ(អ្នកទិញដីពីមន្ត្រីស្រុក) ហើយតុលាការកំពូលបានសម្រេចប្រគល់ដីឲ្យខ្លួនរួចហើយ។ ក្រោយមក ភាគីម្នាក់អះអាងថាជាដីរបស់ខ្លួន ហើយចោទប្រកាន់ជនជាប់ចោទ ពីបទក្លែងបន្លំលិខិតស្នាមឯកជន ប្រព្រឹត្តនៅខេត្តបន្ទាយមានជ័យ កាលពីថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ១៩៩៨ តាមមាត្រា ៥០ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល។ ចៅក្រមស៊ើបអង្កេតរបស់តុលាការខេត្តបន្ទាយមានជ័យ បានចេញដីកាលេខ ០៤ ដលក ចុះថ្ងៃទី ៤ ខែ កុម្ភៈ ឆ្នាំ ២០០២ សម្រេចលើកលែងការចោទប្រកាន់ជនជាប់ចោទពីបទក្លែងបន្លំលិខិតឯកជន។ សាលាឧទ្ធរណ៍ បានចេញសាលដីកាព្រហ្មទណ្ឌលេខ ៦០ ជ ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៣ សម្រេចតម្កល់ដីកាលើកលែងការចោទប្រកាន់លេខ ០៤។ ម្ចាស់បណ្ដឹងសាទុក្ខ បានប្ដឹងសាទុក្ខ។ តុលាការកំពូល សម្រេចទុកជាមោឃៈសាលដីកាព្រហ្មទណ្ឌ ៦០ ជ និងបញ្ជូនសំណុំរឿងព្រហ្មទណ្ឌ តុលាការខេត្តបន្ទាយមានជ័យដើម្បីចាត់ការបន្តទៀតតាមច្បាប់។

៣. **សំអាងហេតុរបស់តុលាការកំពូល៖-** *១. យល់ឃើញថា ការដែលសាលាឧទ្ធរណ៍សម្រេចលើកលែងចោទប្រកាន់លើឈ្មោះ* (ជនជាប់ចោទ) *ពីបទក្លែងបន្លំលិខិតស្នាម ដោយតម្កល់ដីកាលើកលែងការចោទប្រកាន់លេខ ០៤...ដោយសំអាងថា ដីត្រង់ចំណុចទំនាស់ជាដីរបស់សាលាស្រុក អូរជ្រៅ...ឈ្មោះ*(ជនជាប់ចោទ) *បានទិញពីស្រុកកាលពីថ្ងៃទី...ហើយថាតុលាការកំពូលបានសម្រេចជាស្ថាពរប្រគល់ដីនេះឲ្យជនជាប់ចោទហើយ នោះពុំទាន់មានសំអាងហេតុគ្រប់គ្រាន់ទេ ពីព្រោះក្នុងការសម្រេចសេចក្ដីក្នុងរឿងរដ្ឋប្បវេណី តុលាការកំពូលបានជឿជាក់ថា ដីនេះជាដីរបស់អាជ្ញាធរស្រុកដែលលក់ឲ្យជនជាប់ចោទ ប៉ុន្តែក្នុងរឿងក្ដីពេលនេះ ក្រសួងហិរញ្ញវត្ថុ ...បញ្ជាក់ឲ្យឃើញថា ដីទំនាស់ដែលលោក* (មន្ត្រីស្រុក) *លក់ឲ្យជនជាប់ចោទពុំមែនជាដីស្រុកទេ។ ២. យល់ឃើញថា រឿងក្ដីនេះមានពាក់ព័ន្ធដល់ជនដទៃផ្សេងទៀត ដែលបានរៀបចំឯកសារសុទ្ធតែ ធ្វើឲ្យតុលាការជឿតាម ពុំទាន់ត្រូវបានចោទប្រកាន់ និងស៊ើបសួរដើម្បីរកឲ្យឃើញអំពីការទទួលខុសត្រូវរបស់ជនម្នាក់ៗ ក្នុងបទធ្វើសក្ខីកម្មក្លែងក្លាយ។*

*សម្រេចបញ្ជូនសំណុំរឿងទៅ តុលាការខេត្តបន្ទាយមានជ័យ ដើម្បីចាត់ការបន្តទៀតតាមច្បាប់។*

៣០ មីនា ឆ្នាំ ២០០៥